
អ៊ីមែល: advertising@phnompenhpost.com
www.postkhmer.com/special-report

ប៉ុស្តិ៍ សិក្សាអប់រំ


អ៊ីមែល: advertising@phnompenhpost.com
www.postkhmer.com/special-report



# សាលាអន្តរជាតិឯកជនជួយពង្រឹងការអប់រំប្រកបដោយគុណភាព

ការរីកចម្រើនយ៉ាងឆាប់រហ័សនៃសាលាអន្តរជាតិឯកជននៅកម្ពុជា កំពុងផ្លាស់ប្តូរទិដ្ឋភាពអប់រំរបស់កម្ពុជា និងនាំមកនូវឱកាសសិក្សាកាន់តែច្រើនសម្រាប់យុវជនជំនាន់ក្រោយ។

ការចូលរៀននៅសាលាឯកជន ដែលភាគច្រើនបើកដំណើរការដោយក្រុមហ៊ុនបរទេស កំពុងចាប់ផ្តើមបង្កើនគុណភាពវិស័យអប់រំ និងបំពេញគម្លាតផ្គត់ផ្គង់នៅក្នុងប្រព័ន្ធអប់រំផងដែរ។

បច្ចុប្បន្នសាលាអន្តរជាតិជាច្រើន កំពុងបង្រៀនកម្មវិធីសិក្សាដែលមានការប្រកួតប្រជែងខ្លាំង ដោយផ្អែកលើគំរូកម្មវិធីសិក្សារបស់ចក្រភពអង់គ្លេស អាមេរិក សិង្ហបុរី ឬបារាំងជាដើម ដែលជាកម្មវិធីសិក្សាមានការពេញនិយមខ្លាំងនៅតាមបណ្តាប្រទេសជាច្រើន។


លោក ហុក សុទ្ធិ នាយកអង្គការស៊ីប៉ា។

លោក ហុក សុទ្ធិ នាយកអង្គការស៊ីប៉ាបានឲ្យកាសែតភ្នំពេញប៉ុស្តិ៍ដឹងថា ស្ថាប័នអប់រំអន្តរជាតិមានតួនាទីសំខាន់ ពីព្រោះវាជាគំរូមួយសម្រាប់ឲ្យវិស័យអប់រំរបស់យើង ដើម្បីធ្វើយ៉ាងណាឲ្យយើងអភិវឌ្ឍវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា។

«ចំពោះសាលាអន្តរជាតិឯកជននៅកម្ពុជា មានកម្រិតខ្ពស់ជាងគុណភាពអប់រំក្នុងស្រុក ដែលគេបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងស្តង់ដារបស់ប្រទេសគេ។ ស្តង់ដាទាំងនោះភាគច្រើនគឺលើសស្តង់ដាអប់រំរបស់យើង»។

ស៊ីប៉ាគឺជាអង្គការក្រៅរដ្ឋាភិបាលមួយដែលបានជួយលើកកម្ពស់អក្ខរកម្មនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាង២ទសវត្សរ៍មកហើយ។

សាលាឯកជនអន្តរជាតិជាច្រើន កំពុងទាញយកប្រយោជន៍ពីតម្រូវការអប់រំដែលមានគុណភាពពីឪពុកម្តាយដែលមានក្តីប្រាថ្នាខ្ពស់ និងមានជីវភាពធូរធារ ជាពិសេសអ្នករស់នៅក្នុងទីក្រុង ជាកន្លែងដែលសាលាមានគុណភាពមានត្រូវការខ្ពស់។

សាលាឯកជនភាគច្រើនមានបំពាក់ដោយសម្ភារទំនើប បន្ទប់រៀនស្អាត មានហេដ្ឋារចនាសម្ព័ន្ធល្អ គ្រូមានសមត្ថភាពខ្ពស់ ដែលអាចបង្រៀននូវកម្មវិធីសិក្សាដែលមានតម្រូវការខ្ពស់នៅលើទីផ្សារ ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងការចង់បានពីអ្នកដែលមានលទ្ធភាពផងដែរ។

យោងតាមរបាយការណ៍ស្ថិតិ និងសូចនាករអប់រំឯកជនរបស់ក្រសួងអប់រំយុវជន និងកីឡា (ឆ្នាំសិក្សា ២០១៨-២០១៩) បានបង្ហាញថា សិស្សសរុបចំនួន ២១៨,៣៥៧នាក់ បានចុះឈ្មោះចូលរៀននៅសាលាឯកជនចំនួន១២២២សាលា នៅទូទាំងប្រទេស ចាប់ពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់វិទ្យាល័យ។

លោកសុទ្ធិ បន្ថែមថា៖« សាលាអន្តរជាតិទាំងនោះក៏បានរួមចំណែក តបតាមតម្រូវការរបស់ប្រទេសយើងផងដែរ និងតម្រូវការចង់ចេះចង់ដឹងរបស់កូនខ្មែរ ជាពិសេសសម្រាប់គ្រួសារដែលមានលទ្ធភាព និងជីវភាពធូរធារ»។

«សាលាមួយចំនួនក៏យកកម្មវិធីសិក្សាផ្លូវការរបស់កម្ពុជាទៅអនុវត្តដែរ ដើម្បីរៀបចំឲ្យយុវជនដែលចេញពីសាលាទៅ ថ្ងៃក្រោយមកធ្វើការនៅក្នុងប្រទេសកម្ពុជាវិញ។ ចំពោះសាលាមួយចំនួនទៀត គាត់ធ្វើយ៉ាងណាបង្រៀនសិស្សដើម្បីតម្រង់ទិសឲ្យពួកគេចូលប្រឡូកទៅក្នុងទីផ្សារអន្តរជាតិ ដូចជានៅអឺរ៉ុប នៅអាមេរិកជាដើម»។

ប៉ុន្តែលោកក៏បានលើកឡើងអំពីការរីកដុះដាលយ៉ាងខ្លាំងនៃសាលាអន្តរជាតិទាំងអស់នោះថា វាមានតម្លៃថ្លៃដែលគ្រួសារកម្ពុជាភាគច្រើនគ្មានលទ្ធភាពបង់ ហើយអាទិភាពបង្រៀនជាភាសាខ្មែរមានទាប។

លោកលើកឡើងថា៖«ចំពោះកូនខ្មែរមួយចំនួនដែលពួកគេទៅរៀននៅសាលាអន្តរជាតិឯកជន ប៉ុន្តែពួកគេអត់ចេះភាសាខ្មែរ ចេះតែភាសាអង់គ្លេស ដូច្នេះបើគាត់អត់ចេះភាសាខ្មែរ វានឹងក្លាយជាឧបសគ្គមួយ សម្រាប់គាត់ នៅពេលចូលធ្វើការងារនៅក្នុងសង្គមខ្មែរ»។

លោកសុទ្ធិបន្ថែមថា៖«សម្រាប់សាលាអន្តរជាតិឯកជនទាំងនោះ គួរតែមានបង្រៀនជាភាសាខ្មែរ យ៉ាងហោចណាស់សម្រាប់កូនសិស្សខ្មែរ។ ពេលខ្លះឪពុកម្តាយចង់ឲ្យកូនរបស់ខ្លួនចេះភាសាអង់គ្លេសខ្លាំងពេក ធ្វើឲ្យពួកគេគ្មានឱកាសរៀនភាសាខ្មែរ។ ពួកគេអាចចេះនិយាយភាសាខ្មែរ ប៉ុន្តែសរសេរអត់ត្រូវ អានអក្សរអត់ដាច់ ថ្ងៃក្រោយវាអាចប៉ះពាល់ដល់អត្តសញ្ញាណរបស់កូន»៕ ■

# ការគិតស៊ីជម្រៅជួយដោះស្រាយបញ្ហាប្រឈម និងបង្កើតឱកាសសម្រាប់កម្ពុជា

*តើធ្វើដូចម្តេចទើបអាចក្លាយជាអ្នកចែកចាយគំនិតបាន ? តើធ្វើម្តេចទើបគំនិតយើងអាចស័ក្តិសមនឹងចែកចាយបាន ?*

លោកបណ្ឌិត អ៊ុង វ៉ាន់ធឿន សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យន័រតុនហើយលោកក៏ជាវេជ្ជបណ្ឌិតផ្នែកចិត្តវិទ្យាផងដែរនោះថ្លែងថា ទាំងអស់នេះគឺកើតចេញពីការចេះគិតឲ្យបានច្រើនជ្រុង យកហេតុផលជាច្រើនមកថ្លឹងថ្លែង ដោយមានអំណះអំណាង និងបទពិសោធជាក់ស្តែងបន្ទាប់មកគឺចេះវាយតម្លៃ។

ការអប់រំចំណេះដឹងទូទៅ និងបណ្តុះបណ្តាលជំនាញផ្សេងៗពិតជាសំខាន់ និងបានឆ្លើយតបទៅកាន់តម្រូវការទីផ្សារការងារក្នុងសង្គម។ ហើយនៅពេលដែលយើងមានគំនិតដែលល្អ យើងនឹងអាចយកគំនិតមកប្រើប្រាស់ ឬគ្រាន់តែចែកចាយគំនិតនោះយើងក៏អាចរកចំណូលបានដែរ។ ឧទាហរណ៍ ដូចជាក្នុងកម្មវិធី TedTalk ដែលជាកម្មវិធីដ៏ល្បីមួយ ដែលវាគ្មិនគឺមកពីគ្រប់មជ្ឈដ្ឋាន គ្រប់ជាតិសាសន៍ អ្នកខ្លះបកស្រាយពីរបកគំហើញថ្មី អ្នកខ្លះនិយាយពីបទពិសោធផ្ទាល់ខ្លួន។



លោកបណ្ឌិត អ៊ុង វ៉ាន់ធឿន សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យន័រតុន។

លោកបានលើកឡើងថា៖«យើងតែងដឹងថា លុយគឺជារូបិយប័ណ្ណក្នុងជីវភាពប្រចាំថ្ងៃ ប៉ុន្តែក្នុងសតវត្សរ៍ទី២១ ត្រូវបានគេនិយាយថា«គំនិតគឺជារូបិយប័ណ្ណថ្មី»។

យោងតាមលោកសាកលវិទ្យាធិការរង សាស្ត្រាចារ្យដែលកំពុងបង្រៀននៅសាកលវិទ្យាល័យមួយចំនួនបានបង្ហាញអំពីការបារម្ភ ពីការចុះខ្សោយនៃសមត្ថភាពនៃការគិត របៀបនៃការបញ្ចេញគំនិត និងបញ្ចេញមតិ។

«ជាមួយគ្នានេះដែរ យើងក៏សង្កេតឃើញថា ក្នុងបណ្តាញសង្គមក៏ឃើញមានការចែកចាយនូវព័ត៌មានជាច្រើន ដែលព័ត៌មានជាច្រើនគឺជាព័ត៌មានមិនពិត និងគ្មានប្រភពច្បាស់លាស់ ដែលនេះក៏កើតឡើងដោយសារកង្វះការពិចារណាដោយផ្អែកលើភ័ស្តុតាង និងហេតុផលសមរម្យដែរ»។

លោកបណ្ឌិត វ៉ាន់ធឿនបានបន្តថា៖ «យើងមិនអាចគ្រាន់តែបង្រៀនឲ្យគាត់ថាតាមយើងនោះទេ យើងត្រូវរកវិធីដើម្បីឲ្យគាត់ចូលរួមគិត និងបញ្ចេញយោបល់ជាមួយយើង។ យើងគួររិះរកវិធីនានាដើម្បីទាញនិស្សិតឲ្យចូលរួមជាមួយការបង្រៀនដែរ ដោយយើងត្រូវប្រើបច្ចេកទេសឲ្យពួកគាត់ដែលជាសិស្ស និស្សិត ចេះឆ្ងល់, គាត់ចេះយករឿង ឬមេរៀនមកភ្ជាប់ជាមួយជីវភាពប្រចាំថ្ងៃ»។


សាកលវិទ្យាល័យន័រតុននៅក្នុងរាជធានីភ្នំពេញ។

លោកក៏បានលើកឧទាហរណ៍ទាក់ទងនឹងហេតុការណ៍ជាក់ស្តែងដែលកើតឡើងថា៖«នៅពេលដែលមានអ្នកបើកបរម្នាក់បានបើកបុកមនុស្សម្នាក់ស្លាប់ ហើយក៏បានរត់គេចតែត្រូវមនុស្សជាច្រើនចោមរោមវាយសម្លាប់អ្នកបើកបរនោះដោយគិតថាដើម្បីរកយុត្តិធម៌។ ប៉ុន្តែពួកគាត់មិនបានគិតថា អ្នកបើកបរនោះគាត់អាចជាប់ទោសពីបទមនុស្សឃាតដោយអចេតនា ប៉ុន្តែប្រជាជនដែលព័ទ្ធវាយនោះអាចជាប់ទោសពីហិង្សា ឬមនុស្សឃាតដោយចេតនា»។

លោកសង្កត់ធ្ងន់ថា៖«ការដែលចេះគិត និងថ្លឹងថ្លែងអាចបញ្ចៀសយើងពីបញ្ហា ហើយក៏អាចជួយឲ្យយើងរីកចម្រើន ច្នៃប្រឌិតជាគំនិតដែលមានប្រយោជន៍»។

លោកបណ្ឌិតក៏បានលើកយកកម្រងសម្តីរបស់លោកបេនចាមីន ហ្វ្រេងគ្លីន ដែលជាអ្នកនិពន្ធ និងអ្នកទស្សនវិទូនយោបាយដ៏ល្បីរបស់អាមេរិកមួយរូបដែលបានពោលថា៖ «បើអ្នកប្រាប់ខ្ញុំ ខ្ញុំនឹងអាចភ្លេច បើអ្នកបង្រៀនខ្ញុំ ខ្ញុំនឹងចាំ បើអ្នកឲ្យខ្ញុំចូលរួមជាមួយដែរ ខ្ញុំនឹងចេះ»៕ ■

# សាលាអន្តរជាតិ Invictus ត្រៀមផ្តល់គុណភាពអប់រំខ្ពស់នៅកម្ពុជា



**សាលាអន្តរជាតិ** Invictus **ផ្តោតលើការអប់រំគ្រប់ជ្រុងជ្រោយ ភាពជាអ្នកដឹកនាំ ការអភិវឌ្ឍអត្តចរិត ពហុភាសា និងស្តង់ដាគណិតវិទ្យារបស់ប្រទេសសិង្ហបុរី។**

សាលាអន្តរជាតិថ្មីមួយកំពុងត្រៀមខ្លួនចូលក្នុងវិស័យសាលាអន្តរជាតិនៅកម្ពុជា ដែលនឹងនាំមកនូវកម្មវិធីសិក្សាប្រកបដោយគុណភាពខ្ពស់។

សាលាអន្តរជាតិ Invictus ដែលត្រូវបានបង្កើតឡើងនៅប្រទេសសិង្ហបុរីក្នុងឆ្នាំ២០១៥ ដោយសហគ្រិនបច្ចេកវិទ្យាអាហ្វ្រិកខាងត្បូង លោក John Fearon ដើម្បីផ្តល់ការអប់រំកម្រិតខ្ពស់ជាមួយតម្លៃសមរម្យ នឹងបើកដំណើរការក្នុងរាជធានីភ្នំពេញនៅខែមីនាខាងមុខ ជាមួយនឹងតម្លៃ ៨០០០ដុល្លារក្នុង ១ឆ្នាំ។

សាលាអន្តរជាតិនេះនឹងផ្តោតសំខាន់លើការអប់រំគ្រប់ជ្រុងជ្រោយ និងការអភិវឌ្ឍអត្តចរិត ដោយផ្តោតជាពិសេសលើភាពជាអ្នកដឹកនាំ ការបង្រៀនពហុភាសា និងកម្មវិធីសិក្សាគណិតវិទ្យាស្តង់ដារបស់ប្រទេសសិង្ហបុរី ដើម្បីធានាថា សិស្សដែលបញ្ចប់ការសិក្សានឹងមានចំណេះដឹង និងជំនាញច្បាស់លាស់ និងមានជម្រើសច្រើនដើម្បីបន្តការសិក្សានៅគ្រឹះស្ថានឧត្តមសិក្សា។

សាលាអន្តរជាតិ Invictus កំពុងស្ថិតនៅក្នុងដំណាក់កាលពង្រីកសាខារបស់ខ្លួនទៅកាន់ប្រទេសដទៃបន្ទាប់ពីភាពជោគជ័យនៅក្នុងប្រទេសសិង្ហបុរី និងទទួលបានការផ្តល់អនុសាសន៍គាំទ្រយ៉ាងខ្លាំងពីសហគមន៍អន្តរជាតិ។

សាខានៅកម្ពុជានេះគឺបើកដំណើរការ ស្របជាមួយសាខាថ្មី២ផ្សេងទៀតនៅទីក្រុងហុងកុង ហើយក៏មានផែនការនាំយកការអប់រំលំដាប់ខ្ពស់របស់សាលា Invictus ទៅកាន់ប្រទេសថៃផងដែរ។

គណៈគ្រប់គ្រងនៅសាលា Invictus សុទ្ធតែមានបទពិសោធខ្ពស់ ដោយមួយចំនួនបានបម្រើការងារនៅក្រសួងអប់រំសិង្ហបុរីទៀតផង។

ក្នុងនោះលោកស្រី Cecilia Ng ដែលជានាយិកាសាលា លោកស្រីបានរៀបរាប់ថា ចំណូលចិត្តរបស់លោកស្រីគឺការអប់រំ ហើយលោកស្រីពិតជារំភើបណាស់ ដែលបានក្លាយជាថ្នាក់ដឹកនាំរបស់សាលាអន្តរជាតិ Invictus នៅទីក្រុងភ្នំពេញ។

«ការបង្រៀនគឺជាចំណង់ចំណូលចិត្តរបស់ខ្ញុំ ហើយវាគឺជាការងារតែមួយគត់ដែលខ្ញុំបានធ្វើ គឺជាគ្រូបង្រៀន រហូតដល់ក្លាយជានាយិការង ហើយបន្ទាប់មកជានាយិកាសាលានៅក្នុងក្រសួងអប់រំរបស់ប្រទេសសិង្ហបុរី»។

លោកស្រី Ng មានប្រសាសន៍ថា៖«ខ្ញុំពិតជារីករាយណាស់ដលែបានមកកាន់ប្រទេសកម្ពុជា។ខ្ញុំចង់ធ្វើឱ្យមានការខុសប្លែក ដោយផ្តល់នូវជំនាញចាំបាច់ ដូច្នេះ [សិស្ស] អាចចូលរួមចំណែកក្នុងការអភិវឌ្ឍ និងភាពជោគជ័យរបស់ប្រទេសកម្ពុជា»។

នាយិកាដែលមានបទពិសោធរយៈពេល៣០ឆ្នាំរូបនេះ បានបន្តថា ការសិក្សា៣ភាសាគឺភាសាអង់គ្លេស ខ្មែរ និងចិន នឹងក្លាយជាចំណុចពិសេសរបស់សាលាអន្តរជាតិ Invictus ។

«ជាមួយនឹងសកលភាវូបនីយកម្ម វាមានសារៈសំខាន់ណាស់ដែលយើងបង្កើនសមត្ថភាព ពហុភាសាដល់សិស្សរបស់យើង ដោយយើងដឹងថា ការចេះច្រើនភាសានឹងផ្តល់ឱ្យពួកគេនូវការប្រកួតប្រជែងច្រើន។ ការចេះច្រើនជាង១ភាសាជួយបង្កើនការយល់ដឹង និងការប្រាស្រ័យទាក់ទងជាមួយមនុស្សជាច្រើនទៀត។

លោកស្រី Ng បន្ថែមថា៖« ការស្រាវជ្រាវជាច្រើនបានបង្ហាញថា កុមារអាចរៀនភាសាផ្សេងៗបានយ៉ាងឆាប់រហ័ស និងងាយចេះ។ ការរៀនសូត្រច្រើនភាសាគួរតែចាប់ផ្តើមនៅវ័យក្មេង ដូច្នេះហើយទើបសាលាអន្តរជាតិ Invictus មានកម្មវិធីបង្រៀនកុមាររហូតដល់៣ភាសា។

ទស្សនៈរបស់សាលាអន្តរជាតិ Invictus គឺផ្តល់ឲ្យសិស្សនូវការអប់រំគ្រប់ជ្រុងជ្រោយទាំងផ្នែកកម្មវិធីសិក្សា និងក្រៅកម្មវិធីសិក្សា។

«ការសិក្សាគ្រប់ជ្រុងជ្រោយនៅក្នុងថ្នាក់រៀនគឺផ្តោតលើមុខវិជ្ជាបន្ទាប់មកគឺអនុវត្តតាមរយៈបទពិសោធការពិភាក្សា ធ្វើកិច្ចការជាក្រុម និងការសិក្សាជាក់ស្តែង»។

«ការអភិវឌ្ឍអត្តចរិកក៏ជាផ្នែកសំខាន់មួយនៃកម្មវិធីសិក្សារបស់យើងផងដែរ ពីព្រោះយើងជឿជាក់យ៉ាងមុតមាំថា គុណតម្លៃការអប់រំខ្ពស់ និងប្រាជ្ញាទាំង២ត្រូវតែមានតុល្យភាព»។

លោកស្រីលើកឡើងថា៖« ចំពោះភាពជាអ្នកដឹកនាំ ក៏ជាផ្នែកមួយដែលយើងនឹងផ្តោតជាសំខាន់ផងដែរ ពីព្រោះយើងជឿជាក់ថា« កុមារគ្រប់រូប គឺជាអ្នកដឹកនាំ»។

កម្មវិធីសិក្សារបស់យើងធានាថា ឱកាសទាំងនោះនឹងត្រូវបានផ្តល់ដល់កុមារគ្រប់រូបដើម្បីអភិវឌ្ឍជំនាញជីវិត ដូច្នេះពួកគេនឹងមានទំនុកចិត្ត និងអាចប្រាស្រ័យទាក់ទងបានល្អជាមួយសហគមន៍។

អ្នកដឹកនាំពិតប្រាកដគឺជាអ្នកដែលមានចក្ខុវិស័យ សុទិដ្ឋិនិយម ចេះសម្របខ្លួន មានទំនុកចិត្ត មានការសម្រេចចិត្ត និងមានជំនាញទំនាក់ទំនងរឹងមាំ» ។

លោកស្រីក៏លើកឡើងផងដែរថា៖ «ចំពោះជំនាញកុំព្យូទ័រក៏មានបង្រៀននៅក្នុងកម្មវិធីសិក្សារបស់យើងដែរ។ យើងមានគម្រោងបង្រៀនជំនាញសរសេរកូដ និងជំនាញទាក់ទងនឹងព័ត៌មានវិទ្យា»។

ទាំងអស់នេះមានន័យថា សិស្សនៅពេលចាកចេញពីសាលា Invictus ពួកគេមានចំណេះដឹង និងលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីចូលរៀននៅសាកលវិទ្យាល័យ និងជំនាញផ្សេងៗដើម្បីទទួលបានជោគជ័យនៅក្នុងជីវិត។

លោកស្រី Ng ថ្លែងថា៖« យើងចង់ឲ្យសិស្សដែលបញ្ចប់ការសិក្សាជាមួយយើងក្លាយអ្នកដឹកនាំប្រកបដោយទំនុកចិត្ត ជាមួយនឹងទស្សនវិស័យសកលជាមួយនឹងជំនាញរឹងមាំ ដែលអាចបន្តការសិក្សានៅគ្រឹះស្ថានឧត្តមសិក្សានៃជម្រើសរបស់ពួកគេ ហើយជំនាញទន់អាចផ្តល់ឥទ្ធិពលជាវិជ្ជមានដល់មនុស្សជុំវិញខ្លួន និងដឹកនាំពួកគេដោយក្តីស្រឡាញ់ និងការពេញចិត្ត៕ ■



**លោក** John Fearon **ស្ថាបនិកសាលាអន្តរជាតិ** Invictus ។



**លោកស្រី** Cecilia Ng **នាយិកាសាលា** Invictus **នៅភ្នំពេញ ។**

សម្រាប់ព័ត៌មានលម្អិត
http://www.cambodia.invictus.school
https://www.facebook.com/invictusintlschoolcambodia

# សាលាអន្តរជាតិ SCIA អភិវឌ្ឍសមត្ថភាពសិក្សាចម្រុះវប្បធម៌សម្រាប់អនាគតអ្នកដឹកនាំ

ទីក្រុងធំៗនៅជុំវិញពិភពលោកមានវប្បធម៌ចម្រុះកាន់តែកើនឡើង ដូច្នេះដើម្បីឆ្លើយតបទៅនឹងយុគសកលនេះ យុវជនសព្វថ្ងៃគួរតែបណ្ដុះនូវទស្សនៈឲ្យកាន់តែទូលំទូលាយដើម្បីអាចមានសមត្ថភាព ធ្វើការជាមួយមនុស្សដែលមានវប្បធម៌ គំនិត និងទស្សនៈខុសៗគ្នា។

ទោះជាយ៉ាងណា មោទនភាពនៃវប្បធម៌របស់ពួកគេធ្វើឲ្យគេយល់ដឹងអំពីបញ្ហាជាតិ និងការចូលរួមយ៉ាងសកម្មដល់សហគមន៍មូលដ្ឋាន ដែលធានាបាននូវឫសគល់នៃមោទនភាពនៃកេរដំណែលរបស់ពួកគេ។



**សាលា SCIA មានសាស្ត្រាចារ្យចំនួន៤០នាក់ មកពី១៥ប្រទេសផ្សេងៗគ្នាដែលបង្រៀនសិស្សឲ្យយល់អំពីទស្សនវិស័យជាសកល។**

សាលាអន្តរជាតិសិង្ហបុរី (SCIA) ទទួលស្គាល់សារៈសំខាន់នៃការអភិវឌ្ឍសមត្ថភាពចម្រុះវប្បធម៌ ដែលជាផ្នែកមួយនៃបេសកកម្មរបស់ខ្លួន ដើម្បីជំរុញការបំផុសគំនិតអនាគតអ្នកដឹកនាំ។ ក្រៅពីការសិក្សាសាលាអន្តរជាតិ SCIA ក៏ផ្ដល់នូវជំនាញទន់តាមរយៈគំរូសិក្សាគ្រប់ជ្រុងជ្រោយ និងកម្មវិធីសំខាន់ៗមួយចំនួនទៀតដូចជាភាពជាអ្នកដឹកនាំ សហគ្រិនភាព និងមុខវិជ្ជា STEM ជាដើម។

ផ្នែកសំខាន់ៗនៃបទពិសោធសិក្សាចម្រុះវប្បធម៌នៅសាលាអន្តរជាតិ SCIA ការសិក្សា៣ភាសា៖ សិស្សសាលា SCIA តម្រូវឲ្យរៀនជា៣ភាសាគឺភាសាអង់គ្លេស ចិន និងភាសាខ្មែរ។ ការរៀនច្រើនភាសាពីដំបូងនឹងជួយពង្រឹងមូលដ្ឋានគ្រឹះសម្រាប់សិស្សនៅពេលពួកគេបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា។ ខណៈភាសាអង់គ្លេសគឺជាភាសាចម្បងសម្រាប់ការបង្រៀន សាលា SCIA ក៏សង្កត់ធ្ងន់ទៅលើការសិក្សាវប្បធម៌អាស៊ី តាមរយៈការរៀនសូត្រជាភាសាខ្មែរ និងភាសាចិនផងដែរ។

សកម្មភាពវប្បធម៌៖ នៅសាលា SCIA សិស្សចូលរួមអបអរពិធីបុណ្យសំខាន់ៗនៃវប្បធម៌ផ្សេងៗគ្នា ក្នុងនោះរួមមានពិធីបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ បុណ្យសែនព្រះខែ បុណ្យចូលឆ្នាំចិន និងបុណ្យណូអែលជាដើម។

ចំពោះសកម្មភាពសហកម្មវិធីសិក្សាគឺក្លិបវប្បធម៌ខ្មែរ ដែលបើកឲ្យសិស្សមកពីគ្រប់ជាតិសាសន៍ ឲ្យពួកគេរៀនសូត្រពីប្រពៃណី និងទំនៀមទម្លាប់ក្នុងស្រុក។ តាមរយៈការចូលរួមដោយផ្ទាល់ ដែលសិស្សអាចទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅអំពីភាពចម្រុះក្នុងចំណោមមិត្តភក្តិរបស់ពួកគេ និងសារៈសំខាន់នៃឱកាសពិសេសៗទាំងនេះ។

ដំណើរការរៀនសូត្រ និងការចូលរួម៖ មានឱកាសច្រើនសម្រាប់សិស្សសាលា SCIA ក្នុងការធ្វើដំណើរទស្សនកិច្ចទៅបរទេសសម្រាប់ចូលរួមកម្មវិធីសិក្សាផ្សេងៗហើយក៏មានការរចូលរួមការប្រកួតប្រជែងនៅក្រៅប្រទេសផងដែរ។ ក្នុងឆ្នាំសិក្សាកន្លងទៅ សិស្សសាលា SCIA បានធ្វើដំណើរកម្មសិក្សាទៅកាន់ប្រទេសសិង្ហបុរី ចិន ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី។

តំបន់គោលដៅជាច្រើននឹងត្រូវបានកំណត់សម្រាប់២ ឬ៣ឆ្នាំខាងមុខ ដើម្បីពង្រីកការយល់ដឹងរបស់សិស្សឲ្យកាន់តែធំទូលាយ។ សាលា SCIA បានចាប់ដៃគូជាមួយសាលាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (SST) នៅសិង្ហបុរី នៅក្នុងគម្រោងសិក្សាសេវាកម្មសម្រាប់សហគមន៍មូលដ្ឋាននៅលើកោះសូត្រ (Silk Island)។ ដំណើរទស្សនកិច្ចបែបនេះនឹងផ្ដល់នូវវេទិកាមួយដ៏ជាក់លាក់សម្រាប់សិស្សចូលរួម និងរៀនសូត្រពីសមភាគីរបស់ពួកគេដែលមកពីប្រទេសផ្សេងៗ។

ក្រុមសាស្ត្រាចារ្យអន្តរជាតិ៖ ជារៀងរាល់ថ្ងៃ សិស្សសាលា SCIA រៀនសូត្រពីក្រុមគ្រូអន្តរជាតិដែលមានសមត្ថភាព។ សាស្ត្រាចារ្យរបស់សាលាSCIA មានចំនួន៤០នាក់មកពី ១៥ ប្រទេសផ្សេងៗគ្នា ដែលមានបទពិសោធខ្ពស់ក្នុងការបង្រៀនកម្មវិធីសិក្សារបស់ខេមប្រ៊ីដ និងប្រព័ន្ធអប់រំរបស់សិង្ហបុរី។ គ្រូបង្រៀននាំយកចំណេះដឹង និងទស្សនវិស័យចម្រុះរបស់ពួកគេមកក្នុងថ្នាក់រៀន ដោយផ្ដល់ឱ្យសិស្សនូវទស្សនៈចម្រុះ និងជាសកល អមជាមួយថ្នាក់រៀនប្រកបដោយផាសុកភាពនៃសាលា SCIA។

គុណតម្លៃទទួលបានតាមរយៈបទពិសោធ៖ មិនដូចរឿងរ៉ាវជាក់ស្ដែង និងចំណេះដឹងនោះទេ ជំនាញវប្បធម៌ចម្រុះ និងគុណតម្លៃដូចជាការយោគយល់ ឬការគោរពជាដើម មិនអាចរៀនចេះតាមរយៈការបង្រៀន និងការអានសៀវភៅទេ។ វាកើតឡើងតាមរយៈសកម្មភាពដ៏មានអត្ថន័យជាច្រើន ដូចជាបទពិសោធសិក្សា ការចូលរួមក្នុងការប្រកួតប្រជែង ការជួយដល់សហគមន៍ដែលជួបការលំបាកជាដើម ដែលទាំងអស់នេះជាគុណតម្លៃដ៏វិសេសសម្រាប់សិស្សានុសិស្សទុកជាបទពិសោធរបស់ពួកគេ។

តាមរយៈការបង្កើតបទពិសោធ និងបរិយាកាសសិក្សាដ៏សមស្រប សាលាអន្តរជាតិ SCIA កំពុងព្យាយាមបណ្ដុះ និងកសាងសមត្ថភាពសិស្ស តាមរយៈការសិក្សាចម្រុះវប្បធម៌ ដើម្បីឲ្យវាក្លាយជាចំណេះដឹងជាក់ស្ដែងសម្រាប់ពួកគេ ដែលនឹងក្លាយទៅជាអ្នកដឹកនាំនៅថ្ងៃអនាគត នៅក្នុងយុគដែលកំពុងមានការវិវឌ្ឍយ៉ាងឆាប់រហ័សនេះ៕ ■



# ទិចនិកក្នុងការជ្រើសរើសជំនាញដ៏ស័ក្តិសមសម្រាប់អាជីពការងារ

ការជ្រើសរើសនូវជំនាញសម្រាប់អាជីពការងារពេញ១ជីវិតរបស់មនុស្សយើងម្នាក់ៗ គឺជារឿងដែលសំខាន់ និងមិនអាចមើលរំលងបាន។ ប្រសិនបើជ្រើសរើសត្រឹមត្រូវអ្នកនឹងត្រូវខាតបង់ពេលវេលា ប្រាក់កាស ឬក៏អាចទទួលនូវវិប្បដិសារីដ៏ធំធេងចំពោះការស្ថិតនៅក្នុងបរិយាកាសការងារដែលមិនត្រូវនឹងចំណង់ចំណូលចិត្តរបស់ខ្លួន។

អ្នកប្រាកដជាបានជ្រាបខ្លះហើយថា ការជ្រើសរើសនូវជំនាញ ឬ ធ្វើអ្វីមួយដែលផ្ទុយពីចំណង់ចំណូលចិត្តប្រៀបដូចជាការបំផ្លាញនូវទេពកោសល្យដ៏ល្អពីធម្មជាតិរបស់ខ្លួនយ៉ាងដូច្នេះដែរ។ អ្នកត្រូវធ្វើវាទាំងដែលមិនប្រសប់ មិនពេញចិត្ត និងមិនសូវបានផលល្អ។

ផ្អែកលើបទពិសោធ និងការសិក្សាស្រាវជ្រាវកន្លងទៀត មានកត្តាសំខាន់ៗចំនួន ៤ ដែលយើងត្រូវគិតពិចារណាដើម្បីជ្រើសរើសជំនាញមួយដ៏សមស្រប គឺទេពកោសល្យពីធម្មជាតិ ចំណង់ចំណូលចិត្ត តម្រូវការទីផ្សារការងារ និងជ្រើសរើសសាលា/មហាវិទ្យាល័យត្រឹមត្រូវ។

មនុស្សជាច្រើន ជាពិសេសប្អូនៗរៀនថ្នាក់វិទ្យាល័យ តែងសួរខ្លួនឯងថា **«តើខ្ញុំគួររៀនជំនាញអ្វី?»** ខណៈសំណួរដែលពួកគេគួរសួរបំផុតនោះគឺ **«តើជំនាញអ្វីដែលស័ក្តិសមនឹងខ្ញុំ?»** តើអ្នកដឹងទេ ចំណង់ចំណូលចិត្ត គឺជាកត្តាដ៏សំខាន់ក្នុងការនាំផ្លូវអ្នកទៅកាន់វិជ្ជាជីវៈដ៏ស័ក្តិសម។

ការសិក្សាគឺជាការវិនិយោគមួយដែលចំណាយរយៈពេលវែង អ្នកខ្លះអាចនឹងប្រើរយៈពេលជាច្រើនឆ្នាំ ដើម្បីបញ្ចប់ការសិក្សារបស់ពួកគេនៅក្នុងកម្មវិធីមួយ។ ដូច្នេះហើយ យើងម្នាក់ៗគប្បីគិតពិចារណា ស្រាវជ្រាវព័ត៌មានដែលពាក់ព័ន្ធឲ្យបានច្បាស់លាស់ព្រមទាំងស្វែងរកឲ្យឃើញនូវចំណង់ចំណូលចិត្តពិតប្រាកដរបស់ខ្លួន ហើយអ្វីដែលមិនអាចខ្វះបាននោះគឺការជ្រើសរើសសាលារៀនដែលមានបច្ចេកទេសបង្រៀនកម្រិតស្តង់ដា រួមទាំងមានការទទួលស្គាល់លក្ខណៈអន្តរជាតិ។



CamEd **ផ្តល់ការបណ្តុះបណ្តាលជំនាញគណនេយ្យ ហិរញ្ញវត្ថុ និងសវនកម្ម ឈានមុខគេ។**

ជាក់ស្តែងដូចជាវិទ្យាស្ថាន Camed Business School គឺជាវិទ្យាស្ថានដែលផ្តល់ការបណ្តុះបណ្តាលទៅលើជំនាញគណនេយ្យ ហិរញ្ញវត្ថុ និងសវនកម្មស្របទៅតាមស្តង់ដាគណនេយ្យអន្តរជាតិ IFRS ហើយក៏មានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេសនោះគឺសមាគមគណនេយ្យករជំនាញអន្តរជាតិ (ហៅកាត់ថា ACCA ដែលមានការទទួលស្គាល់ ១៨៣ប្រទេសទូទាំងពិភពលោក)។

មិនត្រឹមតែប៉ុណ្ណោះ កម្មវិធីសិក្សា និងការអប់រំផ្នែកបរិញ្ញាបត្រផ្នែកគណនេយ្យ និងហិរញ្ញវត្ថុរបស់វិទ្យាស្ថានក៏បានទទួលស្គាល់ដោយ CFA Institute University Affiliation Program ព្រមទាំងមានការទទួលស្គាល់ស្តង់ដានៃការសិក្សាដោយ ASEAN UNIVERSITY NETWORK និងដោយស្ថាប័ន ISO កម្រិត 9001:2015 ផងដែរ។

លើសពីនេះទៅទៀត រួមផ្សំជាមួយការសិក្សាជាមួយសាស្ត្រាចារ្យដែលមានទាំងបទពិសោធ ចំណេះដឹង និងការទទួលស្គាល់ជាអន្តរជាតិមកពីសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស សិង្ហបុរី ហ្វីលីពីន និងប្រទេសជាច្រើនទៀត និស្សិតនឹងទទួលបាននូវបទពិសោធការអប់រំដ៏អស្ចារ្យទាំងជំនាញវិជ្ជាជីវៈ ជំនាញទន់ ក្រមសីលធម៌ការងារ និងបទពិសោធជាច្រើនទៀត។

និស្សិតនឹងបញ្ចប់ការសិក្សាប្រកបទៅដោយសមត្ថភាព ចំណេះដឹងវិជ្ជាជីវៈ បទពិសោធន៍ ជំនាញទន់ និងក្រមសីលធម៌ពេញលេញសម្រាប់បម្រើការ និងប្រកួតប្រជែងទីផ្សារការងារទាំងស្ថាប័នក្នុងស្រុក និងស្ថាប័នអន្តរជាតិដូចជាក្រុមហ៊ុន PwC KPMG EY និងDeloitte ជាដើម។

សូមចាប់ផ្តើមកសាងជម្រើសដ៏ឆ្លាតវៃ របស់អ្នកនៅថ្ងៃនេះ ជាមួយនឹងវិទ្យាស្ថាន Camed Business School ដោយគ្រាន់តែចូល ទៅកាន់គេហទំព័រ៖ www.cam-ed.com សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់លេខ 023 986 522/ 523/ 960/ 961 ។ ចាប់ផ្តើមទទួលពាក្យពីថ្ងៃនេះ រហូតដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០៕ ■

